ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២៣
# និងលើកទិសដៅការងារឆ្នាំ ២០២៤

## កម្មវិធីទី ២ ÷ កែលម្អលក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ

## “ ការបង្កើនប្រសិទ្ធភាព នៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ”

**បង្ហាញដោយ ÷ ឯកឧត្តម ស្រ៊ិន ពុទ្ធី ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ**

ថ្ងៃអង្គារ - ពុធ ១០ - ១១ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៩ - ២០ ខែមីនា ឆ្នាំ ២០២៤

# មាតិកា


១. សេចក្តីផ្តើម
២. សមិទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ ២០២៣
    ២.១. គម្រោងគាំទ្រដោយថវិកាជាតិ និងដៃគូអភិវឌ្ឍន៍
    ២.២. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការនានា
៣. បញ្ហាប្រឈម
៤. វិធានការដោះស្រាយ
៥. មេរៀន និងបទពិសោធន៍
៦. ទិសដៅការងារបន្ត
៧. សន្និដ្ឋាន

# ១.សេចក្តីផ្តើម

ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់សុខភាពសាធារណៈ និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស ស្ត្រី កុមារ និងជនងាយរងគ្រោះ ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំប្រឹងប្រែងអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ដោយបានដាក់ចេញនូវទស្សនៈវិស័យ “**នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព**”។



# សូចនាករ លទ្ធផល និងគោលដៅក្នុងផែនការសកម្មភាពជាតិដំណាក់កាលទី ២

| លទ្ធផលរំពឹងទុក៖ ត្រឹមឆ្នាំ ២០២៣ ប្រជាពលរដ្ឋនៅជនបទទទួលបានកាន់តែច្រើននូវទឹកសម្រាប់ផឹក ការរស់នៅស្អាត និងអនាម័យខ្លួនប្រាណប្រកបដោយសមធម៌ សុវត្ថិភាព និងតម្លៃសមរម្យ | | | | |
|---|---|---|---|---|
| សូច នាករលទ្ធផល | ទិន្នន័យគោល (%) | ចំណុចដៅ ឆ្នាំ ២០២៣ (%) | គម្លាតដែលត្រូវបំពេញ (ប្រជាពលរដ្ឋ)[២៦] | គម្លាតដែលត្រូវបំពេញ (គ្រួសារ/ខ្នងផ្ទះ) |
| គ្រួសារនៅជនបទប្រើសេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន | ៥៨,៧[២៧] | ៩០ | ៣.៥២៩.៧៧១ | ៧៩៧.៨៣៩ |
| គ្រួសារនៅជនបទប្រើសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានការគ្រប់គ្រងដោយសុវត្ថិភាព | ១៦[២៨] | ៣៣ | ២.២៣០.៩០០ | ៥០៨.៥០០ |
| គ្រួសារនៅជនបទប្រើសេវាអនាម័យជាមូលដ្ឋាន | ៧១,២[២៩] | ៩០ | ២.២៦៨.៨៣៦ | ៥១១.៩២៨ |
| គ្រួសារនៅជនបទប្រើសេវាអនាម័យដែលមានការគ្រប់គ្រងដោយសុវត្ថិភាព | មិនមាន | ៣៥ | ៨.៥៩៣.០៩០ | ១.០៩៨.០០០ |
| គ្រួសារនៅជនបទមានកន្លែងលាងសម្អាតដៃនឹងសាប៊ូ | ៧៧,១[៣០] | ៩០ | ១.៦៩២.៨៦០ | ៣៨៣.០០០ |



# ២.សមិទ្ធផលសម្រេចបានឆ្នាំ ២០២៣

## ២.១ គម្រោងគាំទ្រដោយថវិកាជាតិ និងដៃគូអភិវឌ្ឍន៍

| ឈ្មោះកម្មវិធី / អនុកម្មវិធី | សមិទ្ធផលសម្រេចបានឆ្នាំ ២០២៣ | |
|---|---|---|
| | ថវិកាជាតិ | គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) |
| កម្មវិធីទី ២ ÷ កែលម្អលក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ | | |
| ២.១÷ ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ | | |
| ការសាងសង់អណ្តូងគ្រប់ប្រភេទដែលធន់នឹងការប្រែប្រួលអាកាសធាតុ | ៣៤៩ អណ្តូង | ៣៦៦ អណ្តូង |
| ការសាងសង់ / ស្តារស្រះសហគមន៍ | ០៦ ស្រះ | ០៥ ស្រះ |
| ការសាងសង់អាងត្រងទឹកភ្លៀង | ៣៨ អាង | ៤៩៥៦ ពាង |
| ការសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ | ០៤ កន្លែង | ០៣ កន្លែង |
| ការសាងសង់ស្ថានីយទឹកផឹកដបសហគមន៍ | ០១ កន្លែង | ០ |
| ការងារសាងសង់អាងត្រងទឹកភ្លៀងចំណុះ ១០០០០ លីត្របំពាក់ដោយអាងចម្រោះ | | ០៤ អាង |
| ២.២÷ ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធបរិក្ខាអនាម័យជនបទ | | |
| ផ្គត់ផ្គង់សម្ភារបង្គន់អនាម័យ | ២,៨៥៧ បង្គន់ | ០ |
| រៀបចំបញ្ជីវឌ្ឍនភាពបង្គន់អនាម័យ នៅតាមភូមិគោលដៅ | ១៧៦ ភូមិ | ០ |

| ឈ្មោះកម្មវិធី / អនុកម្មវិធី | | សមិទ្ធផលឆ្នាំ ២០២៣ |
|---|---|---|
| ២.៣÷ ការបង្កើនប្រសិទ្ធភាព នៃការប្រើប្រាស់ទឹកស្អាតជនបទ | | |
| ១ | បណ្តុះបណ្តាលបច្ចេកទេស ថែទាំ និងជួសជុលអណ្តូង | ០១ លើក |
| ២ | អប់រំ ផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត | ០៤ លើក |
| ៤ | រៀបចំផែនការសុវត្ថិភាពទឹកផឹកជនបទ | ១០ លើក |
| ៥ | ត្រួតពិនិត្យ តាមដានការងារទឹកស្អាតជនបទ | ២៥ រាជធានី - ខេត្ត |
| ២.៤ ÷ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ | | |
| ១ | អប់រំ ផ្សព្វផ្សាយ នៅក្នុងសហគមន៍ជនបទឲ្យប្រតិបត្តិអនាម័យល្អនៅក្នុងខេត្តគោលដៅ | ៣៨ ដង |
| ២ | ផ្សព្វផ្សាយកាលើកកម្ពស់អនាម័យជនបទនៅក្នុងខេត្តគោលដៅ | ២៥ វគ្គ |
| ៣ | ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងគ្រូបង្គោល ស្តីពីការពន្លឿនស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល | ០៨ វគ្គ |
| ៤ | ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពការងារសាងសង់បង្គន់អនាម័យនៅភូមិ | ១៦ ខេត្ត |

# គោលការណ៍ណែនាំ សៀវភៅណែនាំបច្ចេកទេស និងឯកសារគតិយុត្តិផ្សេងៗ












# គោលការណ៍ណែនាំ សៀវភៅណែនាំបច្ចេកទេស និងឯកសារគតិយុត្តិផ្សេងៗ









# គោលការណ៍ណែនាំ សៀវភៅណែនាំបច្ចេកទេស និងឯកសារគតិយុត្តិផ្សេងៗ












# ប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ (RWSDM-MRD)




http://rwsdm.mrd.gov.kh

# ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចុះទស្សនកិច្ចស្ថានីយផលិតទឹកស្អាតពីបរិយាកាសសហគមន៍ ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ និងប្រព័ន្ធប្រមូលទឹកភ្លៀង កាលពីថ្ងៃទី ៤ - ៥ ខែកញ្ញា ឆ្នាំ ២០២៣










## ២.២ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការនានា

- ពង្រឹងសមត្ថភាពមន្ត្រីបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរៀបចំផែនការ ដើម្បីជំរុញសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទ
- តាមដានការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទ
- គ្រប់គ្រងប្រព័ន្ធទិន្នន័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (MIS)
- ជំរុញកម្មវិធីសហគមន៍ដឹកនាំអនាម័យ (CLTS)
- អប់រំ ផ្សព្វផ្សាយ និងជំរុញប្រជាពលរដ្ឋនៅសហគមន៍ជនបទឲ្យប្រើប្រាស់ទឹកស្អាត ផឹកទឹកសុវត្ថិភាព និងអនុវត្តអនាម័យល្អ
- ជំរុញ និងផ្សព្វផ្សាយសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលគិតគូរដល់អាហារូបត្ថម្ភ



## ❖ សមិទ្ធផលសម្រេចបានឆ្នាំ ២០២៣

- ➢ អត្រាគ្របដណ្តប់ទឹកស្អាតជនបទជាមូលដ្ឋាន សម្រេចបាន ៨៣.៣ %
- ➢ អត្រាគ្របដណ្តប់ទឹកគ្រប់គ្រងដោយសុវត្ថិភាព ប្រមាណ ២០ %
- ➢ អត្រាគ្របដណ្តប់អនាម័យជនបទជាមូលដ្ឋាន សម្រេចបាន ៨៦.៦ %
- ➢ អត្រាគ្របដណ្តប់អនាម័យប្រកបដោយសុវត្ថិភាព ប្រមាណ ៣៥ %



## ❖ សមិទ្ធផលសម្រេចបានឆ្នាំ ២០២៣

- ខេត្ត ODF ÷ សម្រេចបានចំនួន ០៧ រាជធានី/ ខេត្ត លើគោលដៅ ០៤ រាជធានី/ ខេត្ត
- ស្រុក ODF ÷ សម្រេចបានចំនួន ៦២ ស្រុក/ ក្រុង លើគោលដៅ ៣០ ស្រុក/ ក្រុង
- ឃុំ ODF ÷ សម្រេចបានចំនួន ៦៦៩ ឃុំ/ សង្កាត់ លើគោលដៅ ៦០០ ឃុំ/ សង្កាត់
- ភូមិ ODF ÷ សម្រេចបានចំនួន ៧,២៨២ ភូមិ លើគោលដៅ ១២,៧០០ ភូមិ



## ៣. បញ្ហាប្រឈម

- អត្រាគ្របដណ្តប់ទឹកស្អាត និងអនាម័យនៅតំបន់បរិស្ថានប្រឈមនៅមានភាគរយទាបនៅឡើយ
- ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅតែកើតមានកាន់តែញឹកញាប់ និងខ្លាំងជាងមុនធ្វើឱ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- ធនធានមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការ (ទាំងការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទ)
- ពុំមានធនធានសម្រាប់ធ្វើបញ្ជីសារពើភ័ណ្ឌទិន្នន័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅទូទាំងប្រទេស
- ពុំមានធនធានសម្រាប់តម្កល់ឆ្លើយតប នៅពេលកើតមានគ្រោះមហន្តរាយភ្លាមៗ
- ការផ្លាស់ប្តូរទម្លាប់ប្រជាពលរដ្ឋ និងការយល់ដឹងពីអនាម័យល្អ ការទម្លាប់ប្រើប្រាស់ទឹកស្អាត និងផឹកទឹកសុវត្ថិភាព និងការលាងសម្អាតដៃឱ្យបានត្រឹមត្រូវនៅមានកម្រិត ជាពិសេស ប្រជាពលរដ្ឋមានជីវភាពក្រីក្រ និងតំបន់ដាច់ស្រយាល
- ប្រជាពលរដ្ឋនៅតែមានទស្សនៈពឹងផ្អែកទៅលើជំនួយទើបមិននាំគ្នាសាងសង់សំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

## ៤. វិធានការដោះស្រាយ

- កៀរគរថវិកាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការនានាបន្ថែមទៀត
- បង្កើនកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន សហគមន៍ និងវិស័យឯកជន
- ពង្រឹងការកសាងសមត្ថភាពបច្ចេកទេសដល់ថ្នាក់ក្រោមជាតិ ស្តីពីបច្ចេកវិទ្យាថ្មីៗ ដែលសមស្របទៅនឹងស្ថានភាពវឌ្ឍនភាពជាក់ស្តែង រួមទាំងការបន្សាំ និងធន់ទៅនឹងអាកាសធាតុ
- ពង្រឹងយន្តការសម្របសម្រួល ត្រួតពិនិត្យ និងតាមដានដែលមានស្រាប់ ព្រមទាំងបង្កើនការត្រួតពិនិត្យ និងតាមដាន
- បង្កើនធនធានសម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍នៅតាមមូលដ្ឋានដើម្បីឆ្លើយតបតាមតម្រូវការ
- ជំរុញភាគីពាក់ព័ន្ធក្នុងការបំផុស និងផ្សព្វផ្សាយគ្រប់ទម្រង់នៅសហគមន៍ជនបទ ដើម្បីបង្កើនការប្រើប្រាស់ទឹកស្អាត និងអនុវត្តសារអនាម័យទាំង ៣÷

  ១. ការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ

  ២. ការលាងសំអាតដៃនឹងសាប៊ូក្រោយពេលបន្ទោរបង់ និងមុនពេលបរិភោគអាហារ និង

  ៣. ការផឹកទឹកសុវត្ថិភាព

## ៥. មេរៀន និងបទពិសោធន៍

### ក. ចំណុចខ្លាំង

- មានឯកសារគតិយុត្តិ (គោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពជាតិ គោលការណ៍ណែនាំ និងសៀវភៅណែនាំបច្ចេកទេស ស្តីពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ)
- មានកិច្ចសហការល្អជាមួយក្រសួងពាក់ព័ន្ធ អង្គការ ដៃគូរអភិវឌ្ឍន៍ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត និងអាជ្ញាធរមូលដ្ឋាន
- មានការគាំទ្រ និងយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មានការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាពីអង្គការ និងដៃគូអភិវឌ្ឍន៍
- មានរចនាសម្ព័ន្ធក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- មានយន្តការដឹកនាំ និងសម្របសម្រួល ពីថ្នាក់ជាតិដល់ក្រោមជាតិ (TWG, PWG, DWG, CWG)
- មានធនធានមនុស្សដែលមានចំណេះដឹង និងជំនាញលើការងារបច្ចេកទេស ដែលអាចអនុវត្តការងារបាន

## ៥. មេរៀន និងបទពិសោធន៍

### ខ. ចំណុចខ្សោយ

- ការចូលរួមរបស់សហគមន៍ និងកិច្ចសហការរបស់អង្គការ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននៅមានកម្រិត
- មិនទាន់មានផែនទីគ្រប់គ្រងទឹកក្រោមដី
- ជំនាញបច្ចេកទេសនៅថ្នាក់ជាតិ និងក្រោមជាតិ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅមានកម្រិត ជាពិសេស បច្ចេកវិទ្យាថ្មីៗ
- ការបញ្ជ្រាបការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទៅក្នុងកម្មវិធីវិនិយោគឃុំ/ សង្កាត់ នៅមានកម្រិត
- ការផ្គត់ផ្គង់សម្ភារអនាម័យនៅតំបន់ជនបទ មិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ
- ខេត្តមួយចំនួនមិនមាន អង្គការ ដៃគូអភិវឌ្ឍន៍ អនុវត្តការងារ (ជាពិសេស តំបន់សមុទ្រ)
- មានយន្តការដឹកនាំ និងសម្របសម្រួល ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ (TWG, PWG, DWG, CWG) ប៉ុន្តែ ខេត្តមួយចំនួនមិនទាន់មានដំណើរការល្អ (ប្រជុំមិនទៀងទាត់)

## ៦. ទិសដៅការងារបន្ត

- បន្តសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការកសាងសមត្ថភាពមន្ត្រីជំនាញទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បន្តកៀរគរហិរញ្ញវត្ថុ (ទាំងថវិកាជាតិ និងដៃគូ) សម្រាប់ការងារការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ
- បន្តជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទិន្នន័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- សហការរៀបចំគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិ ស្ដីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅតំបន់ជនបទ (ថ្មី) និងឯកសារគតិយុត្តិនានាដែលចាំបាច់
- ពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងបន្តអនុវត្តយន្តការឱ្យមានប្រសិទ្ធភាព
- បន្តពង្រឹងយន្តការសម្របសម្រួល ក្រុមការងារបច្ចេកទេសការផ្គត់ផ្គងទឹកស្អាត និងអនាម័យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (TWG, PWG, DWG, CWG)

## ៦. ទិសដៅការងារបន្ត (ត)

- បន្តការផ្សព្វផ្សាយអំពីសារអនាម័យទាំង ៣ ទៅដល់ប្រជាពលរដ្ឋ ជាពិសេស តំបន់ដាច់ស្រយាល
- បន្តយកចិត្តទុកដាក់ផ្សព្វផ្សាយ អនុវត្ត និងផ្តល់ឧបត្ថម្ភធនអំពីកម្មវិធីទឹកស្អាត និងអនាម័យជាមួយគ្រួសារក្រីក្រ និងក្រុមដែលងាយរងគ្រោះផ្សេងៗទៀត ដោយមិនទុកនរណាម្នាក់ចោល
- បន្តជំរុញការលើកកម្ពស់ និងអប់រំ ផ្សព្វផ្សាយអំពីការប្រើប្រាស់ និងការថែទាំប្រភពទឹក
- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមហ៊ុនខ្នងអណ្តូងឯកជន
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងវិស័យឯកជនលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

# ៧. សន្និដ្ឋាន

- ការអនុវត្តសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ គឺជាការរួមចំណែកក្នុងយុទ្ធនាការ នៃការជួយកាត់បន្ថយភាពក្រីក្រ និងបានឆ្លើយតបទៅនឹងគោលនយោបាយជាតិ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នីតិកាលទី ៦ នៃរដ្ឋសភារបស់រាជរដ្ឋាភិបាល ។
- ក្រសួងអភិវឌ្ឍន៍ជនបទ ដើរតួនាទីជាអ្នកសម្របសម្រួលការអនុវត្តសកម្មភាព ដើម្បីផ្តល់សេវាទឹកស្អាត និងអនាម័យជនបទ ជូនដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន គឺក្នុងគោលបំណងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ជនបទប្រកបដោយចីរភាព។ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល ជាពិសេស ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមាន **ឯកឧត្តមរដ្ឋមន្ត្រី** ជាប្រមុខបានធ្វើឱ្យការងារការផ្គត់ផ្គង់ទឹក និងអនាម័យជនបទមានការរីកចម្រើនខ្លាំង។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តជំរុញបន្ថែមទៀត ដើម្បីសម្រេចបាននូវទស្សនៈវិស័យផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅតំបន់ជនបទ ឆ្នាំ ២០២៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០៣០ ចំនុចដៅទី ៦.១ និង ៦.២ ។

# សកម្មភាពក្រុមការងារចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃការងារសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ













## សូមអរគុណ
## ចំពោះការយកចិត្តទុកដាក់ស្តាប់ !